# សិទ្ធិមនុស្ស

# សិទ្ធិយើង

## សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនៅកម្ពុជា



៦០
សេចក្តីប្រកាស
ជាសកល
ស្តីពីសិទ្ធិមនុស្ស
១៩៤៨-២០០៨

**សេចក្តីថ្លៃថ្នូរ និង**
**យុត្តិធម៌សំរាប់ទាំងអស់គ្នា**

នេះគឺជាការបោះពុម្ពផ្សាយដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ក្នុងឱកាសខួបលើកទី៦០ នៃការអនុម័តសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស កាលពីឆ្នាំ១៩៤៨ និងខួបលើកទី១៥នៃការអនុម័តរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ១៩៩៣។ ការបោះពុម្ពផ្សាយនេះក៏ធ្វើចំពេលខួបលើកទី៣០ នៃការដួលរលំរបបខ្មែរក្រហមនៅថ្ងៃទី៧ មករា ១៩៧៩ ដែរ ។

អត្ថបទអត្ថាធិប្បាយដោយរូបភាពនេះ ត្រូវបានច្នៃប្រឌិតឡើងដោយមានកិច្ចសហការដ៏ប្រពៃនិងសប្បុរសពីជាងគំនូរថ្លុកពីររូបគឺ លោកសែន សាមន្តដារា និង លោកសំ សារ៉ាត ធ្វើការនៅអង្គការអភិវឌ្ឍន៍សង្គម (CSD) ។

**អង្គការសហប្រជាជាតិ**
**សិទ្ធិមនុស្ស**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស**
**ការិយាល័យប្រចាំកម្ពុជា - ភ្នំពេញ**

# សេចក្តីផ្តើម

យើងកំពុងប្រារព្ធខួបលើកទី៦០នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សក្នុងឆ្នាំ២០០៨នេះ។ នៅក្នុងសេចក្តីប្រកាសនេះ ប្រទេសទាំងអស់នៅលើពិភពលោក បានរួបរួមគ្នា ហើយបានយល់ព្រមលើបញ្ហាសំខាន់ៗជាច្រើន ដែលយើងទាំងអស់គ្នាជាមនុស្សគួរតែមាន ដើម្បីធ្វើឲយើងអាចរស់នៅដោយសប្បាយរីករាយ។ បញ្ហាទាំងអស់នេះ ហៅថាសិទ្ធិមនុស្សរបស់យើង។ សិទ្ធិទាំងនេះគឺជារបស់យើងទាំងអស់គ្នា ពីព្រោះយើងគឺជាមនុស្ស។

កូនសៀវភៅនេះពន្យល់ជាពាក្យពេជន៍អធិប្បាយជាមួយរូបភាពថាហេតុអ្វីបានជាសិទ្ធិមនុស្សនៅក្នុងសេចក្តីប្រកាសជាសកលនេះ មានសារសំខាន់ដល់ប្រជាជនកម្ពុជាទាំងអស់។សេចក្តីប្រកាសជាសកលប្រើពាក្យពេជន៍ដែលប្រជាជនភាគច្រើនពិបាកយល់។ តាមរយៈកូនសៀវភៅនេះ យើងសូមធ្វើការបង្ហាញពីអត្ថន័យសិទ្ធិមនុស្ស នៅក្នុងការអនុវត្តន៍ជាក់ស្តែងដល់ប្រជាជនកម្ពុជា ដោយធ្វើការនិទានរឿងដ៏សាមញ្ញមួយ របស់គ្រួសារកម្ពុជាធម្មតាមួយធ្វើមាតុភូមិនិវត្តន៍ក្រោយពេលសង្គ្រាម។ ការិយាល័យយើងក៏មានភ្ជាប់ជូនតាមរូបភាពនីមួយៗនូវមាត្រាដែលពាក់ព័ន្ធនៃសេចក្តីប្រកាសជាសកលនេះដែលសរសេរជាពាក្យសម្រាយធ្វើឲមនុស្សរាល់រូបអាចយល់បាន។

សេចក្តីប្រកាសនេះ មានលក្ខណៈពិសេសណាស់នៅកម្ពុជា ដោយសារតែវាត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ។ នេះមានន័យថា យើងទាំងអស់គ្នានៅកម្ពុជាគួរតែអាចទទួលបានសិទ្ធិមនុស្សជាមូលដ្ឋាននេះ។

សេចក្តីប្រកាសជាសកលចាប់ផ្តើមដោយការពន្យល់ហេតុអ្វីបានជាសិទ្ធិមនុស្សសំខាន់។

មនុស្សគ្រប់រូបអាចរស់នៅដោយសេរីក្នុងពិភពលោកមួយដែលមានសន្តិភាពនិងយុត្តិធម៌លុះត្រាតែមានការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។

នៅក្នុងអតីតកាល មនុស្សមួយចំនួនបានប្រព្រឹត្តអំពើឃោរឃៅ និងគួរឲភ័យខ្លាចដល់មនុស្សដទៃទៀត ពីព្រោះពួកគេមិនបានយកចិត្តទុកដាក់ដល់សិទ្ធិមនុស្ស។ ឥឡូវនេះ មនុស្សគ្រប់រូប ត្រូវតែមករួបរួមគ្នាដើម្បីធ្វើឲប្រាកដថាយើងមានសេរីភាពនិយាយស្តី និងគិតពីអ្វីដែលយើងចង់គិត ហើយត្រូវធ្វើឲប្រាកដថាយើងមិនត្រូវរស់នៅក្នុងភាពភ័យខ្លាច ភាពអត់ឃ្លាន និងការឈឺចាប់ឡើយ។

ច្បាប់ត្រូវការពារសិទ្ធិមនុស្សរបស់យើង ដូច្នេះយើងមិនចាំបាច់មករួបរួមគ្នាប្រយុទ្ធប្រឆាំងនឹងមនុស្សទាំងឡាយណាដែលព្យាយាមធ្វើឲអន្តរាយដល់សិទ្ធិរបស់យើងឡើយ។

ប្រទេសនីមួយៗ គួរតែស្វែងយល់ពីគ្នាដើម្បីរួមរស់ក្នុងសុខសន្តិភាពទាំងអស់គ្នា។

ប្រជាជនទាំងអស់នៃបណ្តាប្រទេសដែលបានចូលរួមជាមួយអង្គការសហប្រជាជាតិបានយល់ព្រមធ្វើការជាមួយគ្នាដើម្បីការពារសិទ្ធិមនុស្សនិងសុខុមាលភាពរបស់មនុស្សទាំងបុរសនិងស្ត្រីដើម្បីធ្វើឲជីវិតមនុស្សគ្រប់រូបរស់នៅកាន់តែប្រសើរឡើងនៅក្នុងពិភពលោកនេះ។

រដ្ឋាភិបាលនៃបណ្តាប្រទេសដែលជាសមាជិកអង្គការសហប្រជាជាតិ បានសន្យា ដើម្បីធ្វើឲប្រាកដថាសិទ្ធិមនុស្សរបស់យើងត្រូវបានគោរព។ មុននឹងយើងអាចធានាឲមានការគោរពសិទ្ធិមនុស្សរបស់យើង យើងទាំងអស់គ្នាត្រូវតែយល់ពីអ្វីទៅជាសិទ្ធិមូលដ្ឋានរបស់យើង។

អាស្រ័យហេតុនេះ

មហាសន្និបាតអង្គការសហប្រជាជាតិដែលរួមមានអ្នកតំណាងមកពីប្រទេសទាំងអស់នៅលើពិភពលោកនេះ

បានព្រមព្រៀងគ្នាលើ**សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស**នេះ។ ប្រទេសទាំងអស់ និងយើងម្នាក់ៗត្រូវសន្យាចងចាំ និងអនុវត្តតាមដូចអ្វីដែលបានសរសេរនៅក្នុងអត្ថបទនេះ និងធ្វើការឲអស់ពីសមត្ថភាព ដើម្បីធ្វើឲប្រាកដថា មនុស្សគ្រប់រូប អាចទទួលបានសិទ្ធិមនុស្ស។ មនុស្សគ្រប់រូបសុទ្ធតែមានតួនាទីរៀងៗខ្លួនក្នុងការធ្វើឲប្រាកដថាយើងអាចធ្វើបាន។

# កើតមកស្មើភាព និងមានសេរីភាព

នេះគឺជារឿងនិទានរបស់ពូសុខ និងគ្រួសារគាត់

សុខកើតនៅឆ្នាំ១៩៦៨ នៅក្នុងទីរួមខេត្តមួយនៃប្រទេសកម្ពុជា។ វារស់នៅជាមួយឪពុកម្ដាយ និងបងប្រុស។ សុខចងចាំថា ជីវិតរបស់វាកាលពីកុមារភាព គឺជាពេលមួយដ៏សប្បាយរីករាយបំផុត។ វាមិនដែលព្រួយបារម្ភអ្វីទេ។

ឪពុកម្ដាយរបស់វា បានផ្ដល់អ្វីៗទាំងអស់ដែលវាចង់បាន។ ពួកគេបានពន្យល់ វាពីអ្វីដែលខុស អ្វីដែលត្រូវ។ ឪពុកម្ដាយបានបង្រៀនវាថា វាអាចធ្វើអ្វីៗទាំងអស់ដែលវាបានសុបិន្តថានឹងចង់ធ្វើ នៅក្នុងជីវិតរបស់វា ដរាបណាវាមិនបានធ្វើអ្វីប៉ះពាល់ដល់អ្នកដទៃ។ វាគួរតែគោរពរាប់អានអ្នកដទៃស្មើៗគ្នាជាមិត្តភាព និងជួយយកអាសារគ្នាជានិច្ច។



ឪពុកម្ដាយសុខបានបង្រៀនវាពីសិទ្ធិមនុស្ស តែពួកគាត់មិនបានដឹងថា អ្វីៗដែលពួកគាត់បានបង្រៀននេះគឺជាសិទ្ធិមនុស្សនោះទេ។ ទាំងនេះគឺជាមេរៀនដែលសុខនឹងចងចាំពេញមួយឆាកជីវិតរបស់វា។

*សេចក្ដីប្រកាសជាសកលចែងថា:*

**សេចក្ដីថ្លៃថ្នូរ** - ចាប់តាំងពីយើងកើតមក យើងមានសេរីភាព និងគួរតែទទួលបានការគោរពរាប់រកដូចគ្នា ទៅនឹងមនុស្សដទៃទៀតដែរ។ យើងអាចគិតពិចារណា និងយល់ដឹងដោយខ្លួនយើង ពីអ្វីខុសអ្វីត្រូវ។ យើងគួររាប់រកគ្នាដោយមិត្តភាព។ (មាត្រា ១)

**ជីវិត** - យើងទាំងអស់គ្នា មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសិទ្ធិមានសុវត្ថិភាព។ (មាត្រា ៣)


ឈប់!
ប្រគល់របស់ទាំងអស់ឲយើង
បើមិនអញ្ចឹងទេ បាញ់ចោល!
សេរីភាព
សិទ្ធិសុខភាព
សិទ្ធិមានអាហារ

# ខ្មែរក្រហមបានបំផ្លាញសិទ្ធិមនុស្សនៅកម្ពុជា

សុខនៅតូចពេក វាមិនយល់ថានឹងមានរឿងរាវអាក្រក់អាចកើតឡើងនៅលើពិភពលោកនេះ។ វាមិនដឹងអំពីសង្គ្រាមដែលកំពុងបានឆាបឆេះនៅកម្ពុជានាពេលនោះទេ។ វាមិនដែលបានគិតថា ជីវិតរីករាយបែបនេះបានមកដល់ទីបញ្ចប់នោះទេ។

ជាអកុសល ថ្ងៃមួយនៅឆ្នាំ១៩៧៥ សុភមង្គលបែបនេះបានមកដល់ទីបញ្ចប់ភ្លាមនៅពេលដែលទាហានខ្មែរក្រហមបានចូលមកដល់ទីក្រុង ហើយបានបញ្ជាឲប្រជាជនទាំងអស់ចាកចេញពីទីក្រុង។ ប្រជាជនទាំងអស់មានការតក់ស្លុតយ៉ាងខ្លាំង។

ខ្មែរក្រហមបានដកហូតអ្វីៗទាំងអស់ពីប្រជាជន: ផ្ទះសំបែង ទ្រព្យសម្បត្តិទាំងអស់...ព្រមទាំងសុភមង្គលរបស់ពួកគេផង។

ពួកខ្មែរក្រហមបានដកហូតសិទ្ធិមនុស្សពីប្រជាជនទាំងអស់។

ក្នុងកំឡុងពេលជិតបួនឆ្នាំ ខ្មែរក្រហមបានចាត់ទុកប្រជាជនទាំងអស់ថាជាទាសករ។ ប្រទេសកម្ពុជាបានក្លាយទៅជាទីកន្លែងមួយដ៏គ្រៀមក្រំបំផុត ហើយប្រជាជនជាច្រើនបានស្លាប់។ ឪពុកម្តាយសុខ ត្រូវបានសំលាប់: ឪពុកស្លាប់ដោយសាររងការធ្វើទារុណកម្ម ហើយម្តាយស្លាប់ដោយសារការអត់ឃ្លាន និងការបង្ខំឲធ្វើការជាទម្ងន់។ ជាភ័ព្វសំណាងសុខបានរស់រានមានជីវិតពីរបបដ៏ឃោរឃៅនេះ។

*សេចក្តីប្រកាសជាសកលចែងថា:*

**សេចក្តីថ្លៃថ្នូរ** - ចាប់តាំងពីយើងកើតមក យើងមានសេរីភាព និងគួរតែទទួលបានការគោរពរាប់រកដូចគ្នាទៅនឹងមនុស្សដទៃទៀតដែរ។ យើងអាចគិតពិចារណា និងយល់ដឹងដោយខ្លួនយើង ពីអ្វីខុសអ្វីត្រូវ។ យើងគួររាប់រកគ្នាដោយមិត្តភាព។ (មាត្រា ១)

**ជីវិត** - យើងទាំងអស់គ្នា មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសិទ្ធិមានសុវត្ថិភាព។ (មាត្រា ៣)

**ទាសភាព** - គ្មាននរណាម្នាក់ ប្រព្រឹត្តមកលើយើងដូចជាទាសករនោះទេ ហើយយើងក៏មិនត្រូវប្រព្រឹត្តទៅលើនរណាម្នាក់ដូចជាទាសករដែរ។ (មាត្រា ៤)

**ទារុណកម្ម** - គ្មាននរណាម្នាក់ធ្វើទារុណកម្ម ឬប្រព្រឹត្តអំពើឃោរឃៅ ឬផ្តន្ទាឲយើងបាត់បង់តំលៃជាមនុស្សឡើយ។ (មាត្រា ៥)


ជំរំជនភៀសខ្លួន

# *បន្ទាប់មកទៀត ឆាកជីវិតបានរសាត់អណ្តែតមកនៅជំរំ...*

*សុខមិនចង់និយាយពីការឈឺចាប់របស់គាត់ កាលពីអតីតកាលក្រោមរបបខ្មែរក្រហមនោះទេ ពីព្រោះធ្វើឲជីវិតគាត់កាន់តែក្រៀមក្រំយ៉ាងខ្លាំង។*

*ក្រោយរបបខ្មែរក្រហម សង្គ្រាមស៊ីវិលនៅតែបន្ត ហើយសុខត្រូវរត់គេចទៅព្រំដែន។ គាត់បានរស់នៅជំរំជនភៀសខ្លួនអស់ជាច្រើនឆ្នាំ រង់ចាំពេលវេលាមួយដែលគាត់អាចត្រឡប់មកស្រុកកំណើតវិញ។*

*ជួនកាលគាត់មានអារម្មណ៍ឯកោនិងកណ្តោចកណ្តែង។ ប៉ុន្តែបន្ទាប់មក គាត់បានជួបនារីម្នាក់ឈ្មោះចាន់។ គេទាំងពីរបានចាប់ចិត្តស្រឡាញ់គ្នានៅជំរំ ហើយពួកគេបានសំរេចចិត្តរៀបការ ទោះបីជាពួកគេមិនបានដឹងពីអនាគតរបស់ពួកគេ នឹងទៅជាយ៉ាងណាក៏ដោយ។ ក្រោយពីរៀបការរួចភ្លាម ពួកគេបានចាប់ផ្តើមកសាងគ្រួសារមួយ ដោយការផ្តល់កំណើតកូនប្រុសម្នាក់ឈ្មោះនិមិត្ត នៅឯជំរំ។*

*ពូសុខ បានបាត់បង់គ្រួសាររបស់គាត់ក្នុងរបបខ្មែរក្រហម តែឥឡូវនេះ គាត់បានកសាងគ្រួសារផ្ទាល់ខ្លួនថ្មីមួយទៀត។ ទោះជាពេលមានសង្គ្រាមក៏ដោយ គាត់បានចាប់ផ្តើមជីវិតជាថ្មីរបស់គាត់។*

*សេចក្តីប្រកាសជាសកលចែងថា:*

***ជនភៀសខ្លួន*** - ប្រសិនបើមាននរណាម្នាក់ ព្យាយាមធ្វើបាបយើង យើងអាចរត់ទៅប្រទេសមួយទៀតដើម្បីសុំឲគេការពារ។ ក៏ប៉ុន្តែ យើងមិនអាចរត់គេចខ្លួនបានទេ ប្រសិនបើខ្លួនយើងផ្ទាល់បានប្រព្រឹត្តអំពើខុសឆ្គង ដូចជា ធ្វើឲអន្តរាយដល់អ្នកដទៃ ឬមិនគោរពសិទ្ធិមុនុស្សជាដើម។ (មាត្រា១៤)

***អាពាហ៍ពិពាហ៍*** - នៅពេលណាដែលយើងដល់អាយុគ្រប់ការ យើងអាចរៀបការ និងកសាងគ្រួសារមួយបាន។ គ្មាននរណាម្នាក់អាចហាមឃាត់យើងមិនឲរៀបការ ដោយសារតែពណ៌សម្បុរ ប្រទេសកំណើត ឬសាសនារបស់យើងឡើយ។ បុរស និងស្ត្រី មានសិទ្ធិដូចគ្នា នៅពេលដែលពួកគេរៀបការ និងនៅពេលដែលគេលែងលះគ្នា។ គ្មាននរណាម្នាក់ បង្ខំយើងឲរៀបការជាមួយនឹងអ្នកដែលយើងមិនចង់រៀបការជាមួយនោះទេ។

រដ្ឋាភិបាល និងប្រជាជននៃប្រទេសរបស់យើង គួរតែការពារគ្រួសារ និងសមាជិកគ្រួសារយើង។ (មាត្រា ១៦)


ព្រំប្រទល់នៃព្រះរាជាណាចក្រកម្ពុជា
សូមស្វាគមន៍!
លោកមានសេរីភាពធ្វើដំណើរ
ទៅទីណាតាមបំណងលោក។

# ត្រឡប់មកកាន់ភូមិកំណើតវិញ

ថ្ងៃមួយ គាត់ឮសេចក្តីប្រកាសមួយថា សង្គ្រាមបានបញ្ចប់ហើយ ហើយជនភៀសខ្លួនទាំងអស់នឹងត្រូវបានឲត្រឡប់ទៅកាន់ភូមិកំណើតវិញ។ សូម្បី និមិត្ត ទោះវាមិនបានកើតនៅលើទឹកដីកម្ពុជាក៏ដោយ ក៏វាត្រូវបានទទួលស្គាល់ថាជាប្រជាពលរដ្ឋខ្មែរដែរ ហើយក៏ត្រូវបានអនុញ្ញាតឲវិលត្រឡប់មកជាមួយឪពុកម្តាយរបស់វាដែរ។ ប្រជាជនទាំងអស់រំភើបរីករាយយ៉ាងខ្លាំង ដោយបានត្រឡប់មកស្រុកកំណើតវិញ។

ក្នុងពេលមានសង្គ្រាម ការដើរហើរមិនអាចធ្វើបានដោយសេរីនៅទូទាំងប្រទេសនោះទេ។ ក៏ប៉ុន្តែឥឡូវនេះ សន្តិភាពបានវិលមកកម្ពុជាលើផ្ទៃប្រទេសទាំងមូល ប្រជាជនអាចដើរហើរតាមបំណងប្រាថ្នារបស់ពួកគេ។

ប្រជាជនខ្លះបានមកជួបជុំសមាជិកគ្រួសារខ្លួនវិញ និងបានជួបមិត្តភក្តិចាស់ដែលពួកគេបានគិតថាបានបាត់បង់ជីវិតអស់ទៅហើយនៅក្រោមរបបខ្មែរក្រហមនោះ។ ជាច្រើនឆ្នាំក្រោយមក ពូសុខបានជួបជុំបងប្រុសរបស់គាត់វិញ ដែលបានបាត់ខ្លួនអស់ជាច្រើនឆ្នាំមកហើយនោះ។

*សេចក្តីប្រកាសជាសកលចែងថា:*

**សញ្ជាតិ** - យើងទាំងអស់គ្នា គួរតែទទួលបានសញ្ជាតិមួយ។ គ្មាននរណាម្នាក់អាចរារាំងយើងមិនឲទទួលបានសញ្ជាតិពីប្រទេសរបស់យើង ឬសញ្ជាតិពីប្រទេសផ្សេងទៀតដែលយើងចង់បាន ដោយគ្មានហេតុផលសមរម្យនោះឡើយ។ (មាត្រា ១៥)

**ការដើរហើរ** - យើងទាំងអស់គ្នា អាចដើរហើរនៅក្នុងប្រទេសរបស់យើងដោយសេរី។ យើងក៏អាចចេញទៅប្រទេសក្រៅណាមួយ និងវិលត្រលប់មកប្រទេសយើងវិញបានដោយគ្មានការបង្ខិតបង្ខំ។ (មាត្រា ១៣)


ការិយាល័យ
បោះឆ្នោត
UN
បន្ទប់
សម្ងាត់
ហិបឆ្នោត

# ថ្ងៃបោះឆ្នោតៈការចាប់ផ្ដើមថ្មីមួយ

ឥឡូវនេះ កម្ពុជាបានវិលត្រឡប់មករកសន្តិភាពវិញហើយ ការបោះឆ្នោតត្រូវបានរៀបចំឡើង ដែលប្រជាជនទាំងអស់អាចជ្រើសរើសអ្នកណាដែលអាចដឹកនាំប្រទេសបាន។ ការបោះឆ្នោតលើកទីមួយ បានប្រព្រឹត្តទៅកាលពីខែឧសភាឆ្នាំ១៩៩៣ ហើយបន្ទាប់ពីនោះមក ការបោះឆ្នោតជាទៀងទាត់មួយត្រូវបានរៀបចំឡើង។ យោងតាមរដ្ឋធម្មនុញ្ញ ការបោះឆ្នោតត្រូវតែធ្វើឡើងដោយសេរីនិងត្រឹមត្រូវ ហើយប្រជាពលរដ្ឋដែលចង់បោះឆ្នោត គួរតែអាចបោះឆ្នោតបាន។

រដ្ឋធម្មនុញ្ញក៏ធានាការពារសិទ្ធិមនុស្សដល់មនុស្សរាល់រូបនៅកម្ពុជាផងដែរ។ សិទ្ធិមនុស្សនិងប្រជាធិបតេយ្យធ្វើឲសន្តិភាពនៅកម្ពុជាកាន់តែរឹងមាំ និងជាដរាបរៀងទៅ។

*សេចក្ដីប្រកាសជាសកលថែងថា:*

**ប្រជាធិបតេយ្យ** - យើងទាំងអស់គ្នា អាចចូលរួមចាត់ចែងជោគវាសនារបស់ប្រទេសជាតិ តាមរយៈការបោះឆ្នោតជ្រើសរើសអ្នកណាដែលយើងពេញចិត្តឲធ្វើជាតំណាងរបស់យើង ឬក៏ឈរឈ្មោះឲគេបោះឆ្នោតជ្រើសរើសយើងធ្វើជាតំណាងរបស់គេវិញ។

រដ្ឋាភិបាល ត្រូវបានជ្រើសតាំងជាទៀងទាត់តាមរយៈការបោះឆ្នោត ស្របតាមគំនិតរបស់ប្រជាពលរដ្ឋ។ នៅក្នុងការបោះឆ្នោត យើងម្នាក់ៗមានសិទ្ធិបោះឆ្នោតបានតែមួយសន្លឹកប៉ុណ្ណោះ ហើយសន្លឹកឆ្នោតរបស់យើងម្នាក់ៗ មានតំលៃស្មើៗគ្នា។ យើងមិនត្រូវប្រាប់គេ ពីនរណាដែលយើងបោះឆ្នោតឲនោះទេ ប្រសិនបើយើងមិនចង់ប្រាប់នោះ។

យើងទាំងអស់គ្នា មានសិទ្ធិដូចគ្នា ក្នុងការបំរើសេវាសាធារណៈ។ (មាត្រា ២១)

**សន្តិភាព** - ដូច្នេះ នៅពេលណាយើងទទួលបានសិទ្ធិដូចដែលយើងបានអានកន្លងមក នៅក្នុងសេចក្ដីប្រកាសនេះ មនុស្សទាំងអស់នឹងអាចរស់នៅក្នុងសន្តិភាព ទាំងនៅក្នុងសហគមន៍របស់យើង ទាំងរវាងប្រទេសមួយទៅប្រទេសមួយ។ (មាត្រា ២៨)



# លំនៅដ្ឋានថ្មីមួយ

ពូសុខ និងគ្រួសារគាត់បានទៅរស់នៅភូមិកំណើតមីងចាន់។ នៅក្នុងភូមិនេះ ពួកគេទទួលបានដីខ្លះសំរាប់សង់លំនៅដ្ឋាន និងសំរាប់បង្កបង្កើនផល។ នេះជាការប្រពៃណាស់ដែលពួកគេមានលំនៅដ្ឋានមួយផ្ទាល់ខ្លួន បន្ទាប់ពីរស់នៅជំរំអស់ជាច្រើនឆ្នាំ។ លំនៅដ្ឋាននេះ បានផ្តល់សុវត្ថិភាពយ៉ាងសុខសាន្តដល់ពួកគេ ក្រោយពីពួកគេរស់នៅក្នុងស្ថានភាពគ្មានលំនឹងអស់ជាច្រើនឆ្នាំ។

ពូសុខនិងមីងចាន់ បានផ្តល់កំណើតកូនស្រីម្នាក់ឈ្មោះវាសនា ហើយបន្ទាប់មកបានកូនប្រុសម្នាក់ទៀតឈ្មោះបញ្ញា។ ពេលដែលបញ្ញានៅតូចនៅឡើយ វាបានបាត់បង់ជើងម្ខាងដោយសារតែគ្រោះថ្នាក់មួយ។ ក៏ប៉ុន្តែ ហេតុការណ៍នេះមិនបានផ្លាស់ប្តូរវាសនារបស់វាទេ។ទោះជាវាដើរដោយឈើច្រត់ក៏ដោយ ក៏វាអាចមាននិងអាចធ្វើអ្វីៗទាំងអស់ ដូចបងប្រុសនិងបងស្រីវាដែរ។ អ្នករាល់គ្នាស្រឡាញ់រាប់អានវា។

*សេចក្តីប្រកាសជាសកលចែងថា:*

***សន្តិសុខសង្គម*** *- ជាសមាជិកម្នាក់នៅក្នុងសង្គម យើងអាចកសាងជីវិតល្អមួយសំរាប់ខ្លួនយើង និងប្រើប្រាស់ឱកាសល្អៗដែលសង្គមបានផ្តល់ឲ ដើម្បីទាញយកប្រយោជន៍ ដល់ការរស់នៅរបស់យើង។ ប្រសិនបើមាននរណាម្នាក់ជួបការលំបាក យើងទាំងអស់គ្នាគួរតែរួមគ្នា ដើម្បីជួយតាមលទ្ធភាពដែលយើងអាចធ្វើបាន។ (មាត្រា ២២)*

***ជនពិការ*** *- សេចក្តីប្រកាសជាសកលចែងថា សិទ្ធិមនុស្សជារបស់យើងទាំងអស់គ្នា ដោយរាប់បញ្ចូលទាំងជនពិការផង។ យើងទាំងអស់គ្នា មានកាតព្វកិច្ចជាសមាជិកសង្គម ដើម្បីជួយគ្នាទៅវិញទៅមក ធ្វើឲជីវិតកាន់តែប្រសើរបំផុត។ ជនពិការប្រឈមមុខនឹងបញ្ហាពិសេស ប៉ុន្តែបើមានការជួយបន្ថែមតែបន្តិច ពួកគេក៏អាចរស់នៅយ៉ាងពេញលេញ និងសកម្មនៅក្នុងសហគមន៍ដែរ។ (សូមមើលមាត្រា២ និងមាត្រា២៥)*


ក្មួយមិនត្រូវសរសេរ
បែបនេះទេ
ទេ! អនុញ្ញាតឲ្យសិស្សសរសេរពី
អ្វីដែលពួកគេចង់សរសេរចុះ...

# រៀនសូត្រដើម្បីធ្វើឲអនាគតកាន់តែភ្លឺស្វាង

នៅពេលពួកវាធំពេញវ័យ និមិត្ត វាសនា និងបញ្ញា បានទៅរៀននៅសាលាក្នុងភូមិ ដើម្បីរៀនពីអ្វីៗទាំងអស់ដែលពួកគេត្រូវការ ក្នុងការធ្វើឲជីវិតរស់នៅបានសុខសាន្ត និងមានសុភមង្គល។ គ្រូបង្រៀនខ្លះមានការតឹងតែងហួសហេតុពេក ហើយមិនចង់ឲកូនសិស្សនិយាយ សរសេរពីអ្វីដែលពួកគេចង់និយាយ សរសេរនោះទេ។ ប៉ុន្តែនាយិកាសាលាមានប្រាជ្ញាឈ្លាសវៃដោយដឹងថា សាលាគឺជាទីកន្លែងមួយដែលក្មេងៗមិនគួរត្រូវបានហាមឃាត់មិនឲនិយាយនោះទេ តែគួរជាកន្លែងលើកទឹកចិត្តដល់ការដុសខាត់ទេពកោសល្យរបស់ពួកគេ។

នាយិកាសាលាជឿជាក់ថា ក្មេងៗទាំងអស់ត្រូវការចង់ដឹងពីសិទ្ធិមនុស្សរបស់ពួកគេ។

*សេចក្តីប្រកាសជាសកលចែងថា:*

**ការអប់រំ** - យើងទាំងអស់គ្នា អាចទទួលបានការរៀនសូត្រ ហើយជាពិសេសក្មេងៗ គួរតែទៅសាលារៀន។ គ្មាននរណាម្នាក់ តម្រូវឲបង់ប្រាក់ដើម្បីទៅរៀននៅថ្នាក់បឋមសិក្សានោះទេ។ យើងទាំងអស់គ្នាអាចរៀនយកជំនាញណាមួយ ឬក៏បន្តការសិក្សាឲកាន់តែខ្ពស់តាមបំណងប្រាថ្នា។
នៅសាលា យើងអាចបណ្តុះទេពកោសល្យរបស់យើង ហើយគួរតែរៀនពីសិទ្ធិមនុស្ស និងពីរបៀបក្នុងការរាប់អានគ្នាជាមួយអ្នកដទៃ ទោះជាគេមានពណ៌សម្បុរ សាសនា ឬមកពីប្រទេសផ្សេងដទៃទៀតក៏ដោយ។
ឪពុកម្តាយយើង មានសិទ្ធិជ្រើសរើសពីអ្វីដែលយើងចង់រៀន និងពីអ្វីដែលយើងអាចរៀនបាន។
(មាត្រា ២៦)

**ការសម្តែងមតិ** - យើងទាំងអស់គ្នា អាចគិតពីអ្វីដែលយើងចង់គិត និយាយពីអ្វីដែលយើងចង់និយាយ ហើយគ្មាននរណាម្នាក់អាចមកហាមឃាត់យើងមិនឲធ្វើដូច្នេះឡើយ។ យើងអាចផ្លាស់ប្តូរយោបល់គ្នាជាមួយមនុស្សទាំងអស់នៅក្នុងប្រទេសយើង ក៏ដូចជាមួយប្រជាជននៃប្រទេសផ្សេងទៀតផងដែរ។
(មាត្រា ១៩)


អត់ទោសលោក! តើខ្ញុំត្រូវបង់ប្រាក់ប៉ុន្មាន?
អរគុណ! លោកមិនចាំបាច់បង់ប្រាក់ទេ...នេះជាសេវាសុខភាពសាធារណៈ

# មីងចាន់កំពុងពិនិត្យជំងឺនៅមណ្ឌលសុខភាព

ថ្ងៃមួយ នៅពេលមីងចាន់មានផ្ទៃពោះកូនបញ្ញា នាងត្រូវទៅពិនិត្យមើលសុខភាពជាទៀងទាត់ នៅមណ្ឌលសុខភាពក្នុងភូមិ ដើម្បីធ្វើឲច្បាស់ថា ទារកក្នុងផ្ទៃមានសុខភាពល្អ។

ពូសុខព្រួយបារម្ភយ៉ាងខ្លាំង ពីព្រោះគាត់ធ្លាប់ឮថា ត្រូវចំណាយលុយច្រើននៅពេលពិនិត្យសុខភាពម្តងៗ ហើយគ្រួសារគាត់មិនមានប្រាក់គ្រប់គ្រាន់សំរាប់ការចំណាយនេះទេ។ ក៏ប៉ុន្តែ លោកវេជ្ជបណ្ឌិតនៅមណ្ឌលសុខភាពបានពន្យល់គាត់ថា មនុស្សគ្រប់រូបនៅកម្ពុជា មានសិទ្ធិទទួលបានការថែទាំសុខភាពមូលដ្ឋាន។ រដ្ឋធម្មនុញ្ញចែងថា រដ្ឋាភិបាលគួរផ្តល់ការថែទាំសុខភាពដោយឥតបង់ថ្លៃដល់សមាជិកក្រីក្របំផុតរបស់សហគមន៍។ ពូសុខមានអារម្មណ៍ធូរទ្រូងពេលដឹងថា គ្រួសារគាត់នឹងទទួលបានការថែទាំ ប្រសិនបើមាននរណាម្នាក់ធ្លាក់ខ្លួនឈឺ។

មាតា ជាពិសេសនៅពេលមានផ្ទៃពោះ និងទារកត្រូវការកិច្ចគាំពារពិសេស ដើម្បីធ្វើឲច្បាស់ថា អ្វីៗទាំងអស់ដែលពាក់ព័ន្ធមាតានិងទារក ដំណើរការទៅស្រួល។ កុមារគឺជាអនាគតរបស់កម្ពុជា។

*សេចក្តីប្រកាសជាសកលចែងថា:*

**តម្រូវការចាំបាច់** - យើងទាំងអស់គ្នា គួរតែមានអ្វីគ្រប់គ្រាន់តាមតម្រូវការចាំបាច់របស់យើង និងគ្រួសារយើង ដូចជា សេវាសុខភាព អាហារគ្រប់គ្រាន់ សំលៀកបំពាក់ និងលំនៅដ្ឋាន។ យើងគួរតែត្រូវបានទទួលការជួយឧបត្ថម្ភ ប្រសិនបើយើងគ្មានការងារធ្វើ មានជំងឺ ចាស់ជរា ឬស្លាប់ ឬប្រសិនបើយើងគ្មានលទ្ធភាពចិញ្ចឹមជីវិតដោយសារគ្មានជំរើស។ មាតា និងទារក គួរតែទទួលបានការគាំពារពិសេស។ កុមារទាំងអស់ គួរតែត្រូវបានទទួលការរាប់រកដោយស្មើៗគ្នា ដោយមិនគិតថា ឪពុក-ម្តាយរបស់ពួកគេបានរៀបការត្រឹមត្រូវ ឬមិនបានរៀបការនោះទេ។ (មាត្រា ២៥)



## ច្បាប់សំរាប់ការប្រកួតនៃល្បែងជីវិត

និមិត្ត វាសនា និងបញ្ញាចូលចិត្តលេងទាត់បាល់ជាមួយមិត្តភក្តិដទៃទៀតបន្ទាប់ពីការសិក្សា។ អ្នករាល់គ្នានៅក្នុងភូមិប្រមូលផ្តុំគ្នានៅពេលរសៀលដើម្បីចូលរួមការប្រកួតនេះ ដោយមិនគិតថា ពួកគេជាក្មេងប្រុស ឬក្មេងស្រី ជាមនុស្សជំទង់ឬមនុស្សចាស់ ជាអ្នកមានឬអ្នកក្រ សូម្បីតែជនពិការក៏អាចចូលរួមប្រកួតបានដែរ។ អាជ្ញាកណ្តាលត្រូវធ្វើឲប្រាកដថា អ្នកប្រកួតទាំងអស់ លេងគោរពតាមច្បាប់។ តាមវិធីនេះ អ្នកប្រកួតទាំងអស់មានឱកាសត្រឹមត្រូវដើម្បីឈ្នះ។



UDHR

៦០

# សេចក្ដីប្រកាសជាសកល ស្ដីពីសិទ្ធិមនុស្ស

## ១៩៤៨ - ២០០៨

សមភាព - សិទ្ធិនៅក្នុងសេចក្ដីប្រកាសនេះ គឺជាសិទ្ធិរបស់យើងទាំងអស់គ្នា ជារបស់កុមារា និងកុមារី ជារបស់បុរស និងស្ត្រី។ សិទ្ធិទាំងនេះ ជារបស់យើងទាំងអស់គ្នា ទោះជាយើងមានពណ៌សម្បុរខុសគ្នាក៏ដោយ សិទ្ធិទាំងនេះជាសិទ្ធិរបស់យើងទាំងអស់គ្នា ទោះជាយើងនិយាយភាសាផ្សេងគ្នាក៏ដោយ ឬមានគំនិត និងជំនឿ ឬសាសនាផ្សេងគ្នាក៏ដោយ។ សិទ្ធិទាំងនេះជារបស់អ្នកក្រក៏ដូចជារបស់អ្នកមាន ជារបស់គ្រួសារធម្មតា ក៏ដូចជារបស់គ្រួសារអ្នកមានអំណាច។ សិទ្ធិទាំងនេះជារបស់យើងទាំងអស់គ្នា ទោះជាយើងមកពីប្រទេសផ្សេងគ្នា ដែលជាប្រទេសឯករាជ្យ ឬមិនឯករាជ្យក៏ដោយ ក៏សិទ្ធិទាំងនេះ មិនខុសគ្នាដែរ។ (មាត្រា២)

សិទ្ធិមនុស្សគឺដូចជាច្បាប់នៃការប្រកួតបាល់ទាត់ដែរ។ សិទ្ធិមនុស្សធ្វើឲប្រាកដថា មនុស្សគ្រប់រូបមានឱកាសត្រឹមត្រូវដើម្បីចូលរួមក្នុងការប្រកួតនៃល្បែងជីវិត។


ពួកគេសុទ្ធតែជាប្រជាជនកម្ពុជាដូចយើងដែរ ចុះហេតុអ្វីបានជាពួកគេមិនកាន់ព្រះពុទ្ធសាសនា?
មនុស្សរាល់រូបអាចជឿលើសាសនាអ្វីតាមចិត្ត តែយើងទាំងអស់គ្នា នៅតែជាប្រជាជនកម្ពុជា។

# ការប្រារព្ធពិធីផ្សេងៗដែលធ្វើឲយើងខុសៗគ្នា

ពូសុខនិងមីងចាន់ ទាំងពីរនាក់គឺជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយបានចិញ្ចឹមបីបាច់កូនៗរបស់ខ្លួន ឲប្រតិបត្តិតាមព្រះពុទ្ធសាសនាដែរ។ ថ្ងៃមួយនៅតាមផ្លូវទៅវត្ត និមិត្តបានសួរម្តាយរបស់វាថា ហេតុអ្វីបានជាមានគ្រួសារខ្លះនៅក្នុងភូមិ មិនជឿលើអ្វីៗដូចយើង ហើយកាន់សាសនាផ្សេងទៀតខុសពីយើង។ មីងចាន់បានពន្យល់ថា មនុស្សគ្រប់រូបនៅកម្ពុជាមានសិទ្ធិជឿលើអ្វីដែលខ្លួនជឿដោយសេរី។ ទោះបីជាមានប្រជាជនខ្លះកាន់សាសនាឥស្លាម ហើយខ្លះទៀតកាន់គ្រិស្តសាសនា ពួកគេទាំងអស់សុទ្ធតែជាជនកម្ពុជា។

យើងគួរគោរពអ្នកដទៃ បើទោះជានៅពេលយើងមិនមានគំនិតដូចគ្នាក៏ដោយ។ នេះជាប្រការមួយដ៏ត្រឹមត្រូវ មិនត្រឹមតែនៅក្នុងជំនឿសាសនាប៉ុណ្ណោះទេ តែក៏មាននៅក្នុងវិស័យដទៃទៀតនៃឆាកជីវិតរបស់យើងដែរ ដូចជាវិស័យនយោបាយ និងវិទ្យាសាស្ត្រជាដើម។ ទោះជាយើងអាចមានភាពផ្សេងៗគ្នាក៏ដោយ ក៏យើងទាំងអស់ត្រូវបានរួបរួមគ្នាដោយសារយើងទាំងអស់គ្នាគឺជាមនុស្ស ហើយយើងទាំងអស់គ្នាស័ក្តសមនឹងទទួលបានការគោរពដូចគ្នា។

*សេចក្តីប្រកាសជាសកលចែងថា:*

***សាសនា*** *- យើងទាំងអស់គ្នា មានសិទ្ធិជឿលើសាសនារបស់ខ្លួនបានដោយសេរី មានសិទ្ធិផ្លាស់ប្តូរសាសនា និងគោរពប្រតិបត្តិសាសនានោះដោយខ្លួនឯងផ្ទាល់ ឬជាមួយអ្នកដទៃ។*

***គំនិតយោបល់*** *- យើងទាំងអស់គ្នា អាចគិតពីអ្វីដែលយើងចង់គិត និយាយពីអ្វីដែលយើងចង់និយាយ ហើយគ្មាននរណាម្នាក់អាចមកហាមឃាត់យើងមិនឲធ្វើដូច្នេះឡើយ។ យើងអាចផ្លាស់ប្តូរយោបល់គ្នាជាមួយមនុស្សទាំងអស់នៅក្នុងប្រទេសយើង ក៏ដូចជាមួយប្រជាជននៃប្រទេសផ្សេងទៀតផងដែរ។ (មាត្រា ១៩)*

***ការអធ្យាស្រ័យ*** *- សេចក្តីប្រកាសជាសកល អំពាវនាវឲមានការយោគយល់អធ្យាស្រ័យគ្នា ដល់ប្រជាជនដែលខុសពីយើង រួមទាំងប្រជាជនដែលមានគំនិតខុសពីយើងផង។ សូមមើលបុព្វកថាជាឧទាហរណ៍។*


សូមអត់ទោសលោក! នាងខ្ញុំសុំឈប់សំរាក ព្រោះថ្ងៃ នេះខ្ញុំមានជំងឺ
បាទ! មិនអីទេ... កុំព្រួយពីប្រាក់ខែនៅតែ អាចបើកបានដដែល

# ធ្វើការដើម្បីអនាគតភ្លឺស្វាង

ទោះជាមានការងារច្រើនធ្វើនៅផ្ទះក៏ដោយ ក៏មីងចាន់ជ្រើសរើសទៅធ្វើការនៅរោងចក្របន្ថែមទៀត ដើម្បីជួយរកប្រាក់ផ្គត់ផ្គង់គ្រួសារ។ ថៅកែរោងចក្រ គឺជាបុរសម្នាក់មានការយល់ដឹងត្រឹមត្រូវ យកចិត្តទុកដាក់ដល់កម្មករ ហើយប្រព្រឹត្តចំពោះកម្មករកម្មការិនី ដោយការគោរពរាប់អានស្មើៗគ្នានៅកន្លែងធ្វើការ។

ថ្ងៃមួយ មីងចាន់មានជំងឺហើយគ្មានអារម្មណ៍ធ្វើការសោះ។ នាងបារម្ភថា ប្រសិនបើនាងមិនទៅធ្វើការ នាងអាចបាត់បង់ប្រាក់ខែ ឬក៏បាត់បង់ការងារតែម្តង។ ថៅកែនាងពន្យល់នាងថា ច្បាប់ធានាថាកម្មករឈឺត្រូវទទួលបានការការពារ ដូចជាឲឈប់សំរាក ហើយនៅតែទទួលប្រាក់បៀវត្សធម្មតា។ លោកថៅកែគាត់សប្បាយចិត្តនឹងធ្វើបែបនេះ ពីព្រោះលោកយល់ថា កម្មករដែលមានសុខភាពល្អ និងសប្បាយរីករាយ គឺជាកម្មករដែលធ្វើការកាន់តែបានល្អ។

*សេចក្តីប្រកាសជាសកលចែងថា:*

**ការងារ** - យើងទាំងអស់គ្នា គួរតែមានការងារធ្វើ និងអាចជ្រើសរើសការងារដែលយើងចង់ធ្វើដោយសេរី។ យើងត្រូវតែទទួលបានប្រាក់ឈ្នួលគ្រប់គ្រាន់ ដើម្បីយើងអាចផ្គត់ផ្គង់គ្រួសារយើងបាន ហើយថៅកែគួរតែប្រព្រឹត្តមកលើយើងឲបានល្អ។ ប្រសិនបើយើងបាត់បង់ការងារ រដ្ឋាភិបាលគួរតែជួយយើងរហូតដល់យើងអាចមានការងារធ្វើ។ បុរស និងស្រីធ្វើការដូចគ្នា គួរតែទទួលបានកំរៃស្មើគ្នា។ អ្នកធ្វើការទាំងអស់ អាចរួបរួមគ្នា ដើម្បីការពារផលប្រយោជន៍របស់ពួកគេ។ (មាត្រា ២៣)

**ការឈប់សំរាក** - ម៉ោងធ្វើការក្នុងមួយថ្ងៃ មិនគួរយូរពេកទេ។ យើងទាំងអស់គ្នាមានសិទ្ធិឈប់សំរាក និងគួរទទួលបានប្រាក់កំរៃទៀងទាត់សំរាប់ការឈប់សំរាកនេះ។ (មាត្រា ២៤)

ស្ត្រី-គោលការណ៍មួយនៃគោលការណ៍សំខាន់បំផុតទាំងឡាយដែលជាគ្រឹះនៃសេចក្តីប្រកាសជាសកល គឺជាគោលការណ៍ស្មើភាពគ្នារវាងបុរសនិងស្ត្រី ពោលគឺបុរសមិនសំខាន់ជាងស្ត្រីនោះទេ។


ទេ!
ខ្ញុំមិនលក់ដីខ្ញុំទេ ខ្ញុំទុក
សំរាប់ធ្វើស្រែវិញ!

# ការរំខានចូលមកអុកឡុកដល់ភូមិ

ថ្ងៃមួយ ឈ្មួញងីមានប្រាក់ម្នាក់បានចូលមកក្នុងភូមិ។ ឈ្មួញនោះបានឲលុយអ្នកភូមិ ដើម្បីទិញដីរបស់ពួកគាត់។ ឈ្មួញមានបំណងចង់សាងសង់កាស៊ីណូមួយនៅលើដីនេះ។

អ្នកភូមិភាគច្រើន មិនចង់លក់ដីរបស់ខ្លួនទេ ពីព្រោះពួកគេត្រូវការទុកវា សំរាប់បង្កបង្កើនផលចិញ្ចឹមគ្រួសាររបស់គេ។ លើសពីនេះទៅទៀត ពួកគេស្រឡាញ់ភូមិ និងសហគមន៍របស់គេណាស់ ហើយមិនចង់ឃើញភូមិរបស់ពួកគេ ត្រូវបំផ្លាញដោយឈ្មួញទេ។

ក៏ប៉ុន្តែ ឈ្មួញមិនចង់បានចំលើយថាទេពីអ្នកភូមិឡើយ....

*សេចក្តីប្រកាសជាសកលចែងថា:*

**ទ្រព្យសម្បត្តិ** - យើងទាំងអស់គ្នា មានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិលើទ្រព្យសម្បត្តិទាំងឡាយរបស់យើង ហើយគ្មាននរណាម្នាក់មានសិទ្ធិយកទ្រព្យសម្បត្តិយើងដោយគ្មានហេតុផលសមរម្យនោះទេ។(មាត្រា១៧)

មាត្រា២៥នៃសេចក្តីប្រកាសនេះក្តោបយកសិទ្ធិសំខាន់ៗជាច្រើន ទោះជាវាមានចែងតែក្នុងមួយមាត្រានេះក៏ដោយ។ សិទ្ធិទាំងនេះ រួមមានសិទ្ធិលំនៅដ្ឋាន សិទ្ធិមានអាហារគ្រប់គ្រាន់ និងសិទ្ធិទូទៅ ដើម្បីការពារសន្តិសុខលំនៅដ្ឋានយើង។

**តម្រូវការចាំបាច់** - យើងទាំងអស់គ្នា គួរតែមានអ្វីគ្រប់គ្រាន់តាមតម្រូវការចាំបាច់របស់យើង និងគ្រួសារយើង ដូចជា សេវាសុខភាព អាហារគ្រប់គ្រាន់ សំលៀកបំពាក់ និងលំនៅដ្ឋាន។ យើងគួរតែត្រូវបានទទួលការជួយឧបត្ថម្ភ ប្រសិនបើយើងគ្មានការងារធ្វើ មានជំងឺ ចាស់ជរា ឬស្លាប់ ឬប្រសិនបើយើងគ្មានលទ្ធភាពចិញ្ចឹមជីវិតដោយសារគ្មានជំរើស។ មាតា និងទារក គួរតែទទួលបានការគាំពារពិសេស។ កុមារទាំងអស់ គួរតែត្រូវបានទទួលការរាប់រកដោយស្មើៗគ្នា ដោយមិនគិតថា ឪពុក-ម្តាយរបស់ពួកគេបានរៀបការត្រឹមត្រូវ ឬមិនបានរៀបការនោះទេ។ (មាត្រា ២៥)



# សហគមន៍រួបរួមគ្នា

ឈ្មួញបន្តកៀបសង្កត់អ្នកភូមិឲលក់ដីនោះ ហើយមានអ្នកភូមិមួយចំនួន ត្រូវបានឈ្មួញបញ្ចុះបញ្ចូលដោយផ្តល់លុយឲយ៉ាងច្រើន។ ឈ្មួញនេះមើលទៅហាក់ដូចជាអ្នកមានអំណាចម្នាក់។

ពូសុខដឹងថាមធ្យោបាយដែលល្អបំផុតដើម្បីការពារភូមិគឺត្រូវប្រមូលអ្នកភូមិទាំងអស់ឲរួបរួមគ្នា។ គាត់បានរៀបចំការជួបប្រជុំអ្នកភូមិមួយ ដើម្បីសំរេចថាត្រូវធ្វើអ្វីខ្លះ។ ឈ្មួញមិនសប្បាយចិត្តសោះ ហើយព្យាយាមរារាំងមិនឲការជួបប្រជុំនេះកើតឡើង។ ក៏ប៉ុន្តែ អ្នកភូមិដឹងថា ពួកគេមានសិទ្ធិជួបប្រជុំនិងពិភាក្សាពីបញ្ហាសំខាន់ៗជាមួយគ្នា។

អ្នកភូមិទាំងអស់បានព្រមព្រៀងគ្នាថា សហគមន៍របស់គេមានតំលៃធំធេងណាស់សំរាប់ពួកគេពោលគឺធំធេងជាងលុយដែលឈ្មួញផ្តល់ឲ ហើយពួកគេត្រូវការរួបរួមគ្នាដើម្បីការពារសហគមន៍របស់ពួកគេ។

*សេចក្តីប្រកាសជាសកលចែងថា:*

**ការជួបជុំ** - យើងទាំងអស់គ្នា អាចជួបប្រជុំគ្នាបានដោយសន្តិវិធី ឬក៏ចូលរួមក្នុងការប្រជុំជាមួយអ្នកដទៃដោយសន្តិវិធី។ ការបង្ខំអ្នកណាម្នាក់ឲចូលរួមក្នុងក្រុមណាមួយ គឺជាប្រការ ឬអំពើមិនត្រឹមត្រូវទេ។ (មាត្រា ២០)

**សហគមន៍** - យើងទាំងអស់គ្នា អាចចូលរួមចំណែកក្នុងសហគមន៍ ដើម្បីធ្វើឲជិវិតយើងកាន់តែប្រសើរ។ ច្បាប់ត្រូវតែសរសេរឲបានច្បាស់ថា យើងទាំងអស់គ្នាអាចទទួលបានសិទ្ធិមនុស្ស ដោយសុខដុមរម្យនា ជាមួយអ្នកដទៃ។ ច្បាប់ត្រូវធានាឲមនុស្សគ្រប់រូបចេះគោរពគ្នាទៅវិញទៅមក ហើយមនុស្សគ្រប់រូបត្រូវតែគោរពច្បាប់ផងដែរ។ (មាត្រា ២៩)


ដោះលែងខ្ញុំទៅ!
ខ្ញុំមិនបានធ្វើអ្វីខុសទេ! មានតែតុលាការទេ
មានអំណាចចាប់ខ្លួនខ្ញុំ!
ណេះលោក១០០ដុល្លា
ទៀតប្រសិនបើលោក
អាចបន្តឃុំខ្លួនវាបាន។

# ពូសុខត្រូវបានផ្តន្ទាទោសដោយសារតែគាត់ជាមនុស្សល្អ

ឈ្មួញនោះមានការខឹងសំបារនឹងពូសុខយ៉ាងខ្លាំង ដោយសារពូសុខបានរៀបចំការជួបប្រជុំអ្នកភូមិនោះ។ ឈ្មួញនោះបានព្យាយាមធ្វើឲអ្នកភូមិកុំជឿពូសុខ ដោយប្រាប់អ្នកភូមិថា ពូសុខគឺជាមនុស្សអាក្រក់។ ក៏ប៉ុន្តែ គ្មានអ្នកភូមិណាម្នាក់ជឿឈ្មួញនោះទេពីព្រោះអ្នកភូមិដឹងថា ពូសុខគឺជាមនុស្សល្អ។

បន្ទាប់មក ឈ្មួញនោះបានព្យាយាមឲប៉ូលីសចាប់ខ្លួនពូសុខ ពីការរៀបចំការជួបប្រជុំនោះ។ ប៉ុន្តែប៉ូលីសប្រាប់ថា ពូសុខមិនបានធ្វើអ្វីខុសនឹងច្បាប់ទេ។ ពូសុខគ្រាន់តែអនុវត្តសិទ្ធិរបស់គាត់ជាពលរដ្ឋកម្ពុជាម្នាក់ប៉ុណ្ណោះ។

ដូច្នេះ ឈ្មួញនោះបានរៀបចំឲមានការចាប់ពង្រត់ពូសុខ និងចាក់សោរបង្ខាំងគាត់ដោយបុរសម្នាក់ក្លែងខ្លួនជាប៉ូលីស។ បុរសម្នាក់នេះ ចិត្តអាក្រក់ណាស់ ហើយប្រព្រឹត្តមកលើពូសុខយ៉ាងកំរោល។ ពូសុខ មិនសប្បាយចិត្តសោះ គាត់មិនដែលមានអារម្មណ៍បែបនេះទេចាប់តាំងពីការដួលរលំរបបខ្មែរក្រហមមក។

*សេចក្តីប្រកាសជាសកលចែងថា:*

**ភាពឯកជន (រឿងផ្ទាល់ខ្លួន)** - គ្មាននរណាម្នាក់ ត្រូវបានអនុញ្ញាតឲនិយាយសំអុយ ឬរឿងមិនពិតអំពីយើង ចូលផ្ទះយើង បើកមើលសំបុត្ររបស់យើង ឬក៏មករំខានយើង ឬគ្រួសារយើង ដោយគ្មានហេតុផលសមរម្យនោះទេ។ (មាត្រា ១២)

**ពន្ធនាគារ (គុក)** - គ្មាននរណាម្នាក់អាចឃាត់ខ្លួនយើង ឬដាក់យើងនៅក្នុងគុក ឬដេញយើងចេញទៅប្រទេសមួយទៀត ដោយមិនត្រឹមត្រូវ ឬដោយគ្មានហេតុផលត្រឹមត្រូវនោះទេ។ (មាត្រា ៩)



# សេចក្ដីថ្លៃថ្នូរនិងយុត្តិធម៌សំរាប់ទាំងអស់គ្នា

ឈ្មួញជឿជាក់ថា អ្នកភូមិនឹងយល់ព្រមលក់ដីនោះឲគាត់ បើពូសុខមិនជាប់ពាក់ព័ន្ធនឹងបញ្ហានេះ។ ក៏ប៉ុន្តែ ឈ្មួញនោះយល់ខុសស្រឡះ។ អ្នកភូមិទាំងអស់ចូលចិត្ត និងគោរពពូសុខ ហើយដឹងថាច្បាប់ស្ថិតនៅខាងពួកគាត់រួចទៅហើយ។ គ្រាន់តែជាឈ្មួញមានប្រាក់ មិនមែនមានន័យថា គាត់នៅពីលើច្បាប់នោះទេ។

អ្នកភូមិ បានប្ដឹងទៅប៉ូលីសពីការចាប់ខ្លួន និងឃុំខ្លួនពូសុខដោយខុសច្បាប់នេះ។ ពួកអ្នកភូមិបានទាមទារឲរកយុត្តិធម៌ជូនពូសុខ និងជូនភូមិពួកគាត់។ ពួកគាត់សំរេចចិត្តទៅរកច្បាប់ឲជួយការពារសិទ្ធិរបស់ពួកគាត់ ពីព្រោះច្បាប់ត្រូវបានសន្មត់ថា ការពារមនុស្សទាំងអស់ដោយយុត្តិធម៌ និងស្មើភាពគ្នា។

ច្បាប់ការពារសិទ្ធិមនុស្សនៅកម្ពុជា។

ឈ្មួញនោះរីករាយនឹងទៅតុលាការ ពីព្រោះគាត់គិតថា គាត់អាចឲលុយចៅក្រមដើម្បីកាត់សេចក្ដីឲគាត់ឈ្នះ។

*សេចក្ដីប្រកាសជាសកលចែងថា:*

ច្បាប់ – ច្បាប់ត្រូវសរសេរឲបានច្បាស់ថា យើងទាំងអស់គ្នាអាចទាមទារសិទ្ធិមនុស្សរបស់យើង តាមរយៈច្បាប់ ហើយគ្មាននរណាម្នាក់ត្រូវបានបដិសេធចោលនោះទេ។ (មាត្រា ៦)

ច្បាប់ – យើងទាំងអស់គ្នា ត្រូវបានការពារដោយច្បាប់ តាមវិធីដូចគ្នា ដូចអ្នកដទៃទៀតដែរ។ ច្បាប់ត្រូវតែអនុវត្តដូចៗគ្នា ចំពោះមនុស្សគ្រប់រូប (ឬមនុស្សគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះ មុខច្បាប់)។ (មាត្រា ៧)


ខ្ញុំនឹងស្តាប់អំណះអំណាងពីគ្រប់ភាគី
ទាំងអស់ និងពិនិត្យរាល់ភស្តុតាង
មុននឹងខ្ញុំធ្វើសេចក្តីសំរេចតាមច្បាប់
ព្រះរាជអាជ្ញា
ចៅក្រម
មេធាវី

# តុលាការសំរេច

ពូសុខ និងឈ្មួញ ត្រូវបាននាំខ្លួនមកតុលាការ ដើម្បីពន្យល់ពីវិវាទរបស់ពួកគេ។ ភាគីទាំងពីរសុទ្ធតែមានតំណាងដោយមេធាវីដែលចេះច្បាប់ ហើយអាចលើកយកអំណះអំណាងមកនិយាយជំនួសពួកគេ។

ចៅក្រម ស្តាប់អំណះអំណាងរបស់ភាគីទាំងពីរដោយយកចិត្តទុកដាក់ និងពិនិត្យមើលភស្តុតាងទាំងអស់មុននឹងលោកស្រីចៅក្រមធ្វើការសំរេចចិត្ត។

លោកស្រីចៅក្រមរកឃើញថា ពូសុខមិនបានប្រព្រឹត្តបទល្មើសអ្វីនោះទេ ប៉ុន្តែគាត់គ្រាន់តែអនុវត្តសិទ្ធិមនុស្សរបស់គាត់ដែលធានាការពារដោយច្បាប់កម្ពុជាប៉ុណ្ណោះ។ លើសពីនេះ លោកស្រីចៅក្រមបានរកឃើញថា ឈ្មួញនោះមានពិរុទ្ធភាព(ទោស) ពីបទចាប់ពង្រត់មនុស្ស និងអំពើពុករលួយ។ ឈ្មួញនោះគិតខុស ដោយគាត់គិតថា គាត់អាចសូកចៅក្រមបាន។

*សេចក្តីប្រកាសជាសកលចែងថា:*

**ច្បាប់** - យើងទាំងអស់គ្នា អាចសុំការជួយពីអ្នកដទៃដែលចេះច្បាប់ នៅពេលដែលសិទ្ធិតាមផ្លូវច្បាប់របស់យើងមិនត្រូវបានគោរព។ (មាត្រា ៨)

**យុត្តិធម៌** - ប្រសិនបើនរណាម្នាក់ចោទយើងថារំលោភច្បាប់ បញ្ហានេះត្រូវលើកយកទៅកាត់សេចក្តីនៅក្នុងសវនាការមួយ ដែលមានអ្នកដទៃផ្សេងទៀតចូលរួមស្តាប់។ អ្នកកាត់សេចក្តី មិនគួរឲ្យអ្នកដទៃមកបង្គាប់បញ្ជាទេ គាត់ត្រូវតែសំរេចពីអ្វីដែលជាការពិត និងការមិនពិតតែប៉ុណ្ណោះ។ (មាត្រា ១០)

**យុត្តិធម៌** - ប្រសិនបើយើងត្រូវជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ យើងត្រូវបានចាត់ទុកថាជាមនុស្សគ្មានទោស រហូតទាល់តែមានភស្តុតាងបង្ហាញនៅក្នុងសវនាការមួយប្រកបដោយភាពយុត្តិធម៌ ថាយើងមានកំហុស។ យើងម្នាក់ៗ ត្រូវបានអនុញ្ញាត្តឲការពារខ្លួនដោយខ្លួនឯង។ គ្មាននរណាម្នាក់ អាចថ្កោលទោសយើង ឬដាក់ទោសយើងចំពោះអ្វីដែលយើងមិនបានធ្វើនោះទេ។ (មាត្រា ១១)



# អ្នកភូមិទាំងអស់ប្រារព្ធពិធីតាមរបៀបទំនៀមទំលាប់ខ្មែរ

យប់នោះ អ្នកភូមិទាំងអស់ បានរៀបចំពិធីជប់លៀងមួយ។ ពួកគាត់សប្បាយរីករាយ ដោយសារពួសុខមានសេរីភាពវិញ ហើយសិទ្ធិនានារបស់ពួកគាត់ដែលផ្តល់ឲដោយរដ្ឋធម្មនុញ្ញ ត្រូវបានការពារ។ អនាគតសហគមន៍របស់ពួកគាត់ និងគ្រួសារពួកគាត់ ត្រូវទទួលបានការការពារ។

អ្នកភូមិបានរាំច្រៀង និងប្រារព្ធពិធីតាមទំនៀមទំលាប់ខ្មែរ ដូចដែលបុព្វការីជនរបស់ពួកគាត់បានបន្សល់ទុកជាច្រើនជំនាន់មកហើយ។ វប្បធម៌ខ្មែរ បង្រៀនប្រជាជនកម្ពុជាឲចេះគោរពអ្នកដទៃ និងប្រព្រឹត្តទៅលើអ្នកដទៃដោយមេត្តាករុណា និងសេចក្តីថ្លៃថ្នូរ។

សិទ្ធិមនុស្សក៏បង្រៀនវប្បធម៌ដូចខាងលើនេះដែរ។ យើងគួរតែចូលរួមទាំងអស់គ្នា និងធ្វើឲច្បាស់ថា មនុស្សគ្រប់រូបនៅកម្ពុជា អាចទទួលបានសិទ្ធិមនុស្សរបស់ពួកគេដោយរីករាយ។

*សេចក្តីប្រកាសជាសកលចែងថា:*

**វប្បធម៌** – យើងទាំងអស់គ្នាអាចចូលរួមក្នុងជីវភាពវប្បធម៌សហគមន៍ ទទួលផលពីសិល្ប: និងទទួលបានគុណប្រយោជន៍ពីរបកគំហើញថ្មីៗនៃវិទ្យាសាស្ត្រ និងពីស្នាដៃល្អៗដែលគេបានធ្វើ។ ប្រសិនបើយើងបង្កើតបានស្នាដៃអ្វីមួយពិសេស ដូចជាសរសេរសៀវភៅ ឬគូរគំនូរ យើងនឹងទទួលបានប្រយោជន៍ពីស្នាដៃទាំងនេះ ហើយគ្មាននរណាម្នាក់អាចលួចគំនិត ស្នាដៃយើងបានឡើយ។ (មាត្រា ២៧)

**សន្តិភាព** – ដូច្នេះ នៅពេលណាយើងទទួលបានសិទ្ធិដូចដែលយើងបានអានកន្លងមក នៅក្នុងសេចក្តីប្រកាសនេះ មនុស្សទាំងអស់នឹងអាចរស់នៅក្នុងសន្តិភាព ទាំងនៅក្នុងសហគមន៍របស់យើង ទាំងរវាងប្រទេសមួយទៅប្រទេសមួយ។ (មាត្រា ២៨)

គ្មាននរណាម្នាក់ អាចប្រើសេចក្តីប្រកាសនេះ ដើម្បីនិយាយដោះសារ ពីការធ្វើឲខូចខាតដល់សិទ្ធិរបស់អ្នកដទៃថាជាការត្រឹមត្រូវ ដោយអះអាងថា ពួកគេគ្រាន់តែព្យាយាមចង់ការពារសិទ្ធិរបស់ខ្លួនតែប៉ុណ្ណោះ។ មិនអាចទទួលយកបានទេ ចំពោះការធ្វើឲខូចខាតដល់សិទ្ធិអ្នកដទៃ។ (មាត្រា ៣០)

# សេចក្តីប្រកាសជាសកល ស្តីពី សិទ្ធិមនុស្ស

## បុព្វកថា

*ដោយយល់ឃើញថា* ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត និងសិទ្ធិស្មើភាពគ្នា និងសិទ្ធិមិនអាចលក់ដូរ ផ្ទេរ ឬដកហូតបានរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាពយុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក ។

*ដោយយល់ឃើញថា* ការមិនទទួលស្គាល់ និងការប្រមាថមើលងាយសិទ្ធិមនុស្ស នាំឱ្យមានអំពើព្រៃផ្សៃសាហាវយង់ឃ្នង ធ្វើឱ្យក្តៅក្រហាយដល់សតិសម្បជញ្ញៈមនុស្សជាតិ និង *ថា* ការឈានដល់ពិភពលោកមួយដែលមនុស្សទាំងឡាយ មានសេរីភាពក្នុងការនិយាយស្តី និងជំនឿ និងភាពរួចផុតពីការភ័យខ្លាច និងទុគ៌តភាព ត្រូវបានប្រកាសថាជាសេចក្តីប្រាថ្នាដ៏ខ្ពស់បំផុតរបស់មនុស្សទូទៅ ។

*ដោយយល់ឃើញថា* ជាការចាំបាច់ដែលសិទ្ធិមនុស្ស ត្រូវតែបានការពារដោយនីតិរដ្ឋ ដើម្បីជៀសវាងកុំឱ្យមនុស្សបង្ខំចិត្តជាចុងក្រោយបង្អស់ បះបោរប្រឆាំងទល់នឹងអំណាចផ្តាច់ការ និងការគាបសង្កត់ ។

*ដោយយល់ឃើញថា* ជាការចាំបាច់ ដែលត្រូវលើកស្ទួយការពង្រីកទំនាក់ទំនងជាមិត្តភាពរវាងប្រជាជាតិនានា ។

*ដោយយល់ឃើញថា* ប្រជាជាតិទាំងឡាយនៃសហប្រជាជាតិ បានប្រកាសបញ្ជាក់សារជាថ្មីក្នុងធម្មនុញ្ញសហប្រជាជាតិនូវជំនឿរបស់ខ្លួន ទៅលើសិទ្ធិមូលដ្ឋាននៃមនុស្ស លើសេចក្តីថ្លៃថ្នូរលើតម្លៃរបស់មនុស្ស និងលើសមភាពនៃសិទ្ធិរវាងបុរស និងស្ត្រី ហើយប្តេជ្ញាលើកស្ទួយវឌ្ឍនភាពសង្គម និងកម្រិតជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើងក្នុងសេរីភាពកាន់តែទូលំទូលាយ ។

*ដោយយល់ឃើញថា*ដោយសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ រដ្ឋជាសមាជិកទាំងអស់ សន្យាធ្វើឱ្យមានការគោរពជាសកល និងការប្រតិបត្តិនូវសិទ្ធិ និងសេរីភាពមូលដ្ឋាន។

*ដោយយល់ឃើញថា* ការយល់ដូចគ្នាមួយអំពីសិទ្ធិ និងសេរីភាពទាំងនេះ មានសារសំខាន់បំផុត ដើម្បីបំពេញនូវការសន្យាខាងលើ ។

*អាស្រ័យហេតុនេះ* មហាសន្និបាតប្រកាសថា :

*សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនេះ* ជាឧត្តមគតិរួម ដែលប្រជាពលរដ្ឋគ្រប់ៗប្រទេស និងប្រជាជាតិទាំងអស់ ត្រូវធ្វើឱ្យបានសម្រេច ដើម្បីឱ្យបុគ្គលគ្រប់ៗរូប និងអង្គការសង្គមទាំងអស់ ដោយរក្សាខ្ជាប់ជានិច្ចក្នុងស្មារតីរបស់ខ្លួននូវសេចក្តីប្រកាសនេះ ខិតខំប្រឹងប្រែងបណ្តុះបណ្តាលការគោរពសិទ្ធិ និងសេរីភាពទាំងនេះ តាមរយៈការបង្រៀន និងការអប់រំ ហើយខំប្រឹងប្រែងធានាឱ្យមានការទទួលស្គាល់ និងការអនុវត្តន៏ជាសកល និងដោយស័ក្តិសិទ្ធិនូវសិទ្ធិ និងសេរីភាព ដោយវិធានការជាតិ និងអន្តរជាតិ ដែលមានលក្ខណៈរីកចម្រើនជាលំដាប់ ទាំងក្នុងចំណោមប្រជាពលរដ្ឋនៃរដ្ឋសមាជិក ទាំងក្នុងចំណោមប្រជាពលរដ្ឋដែនដីដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃរដ្ឋទាំងនោះ ។

**មាត្រា១:** មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិ។ មនុស្សមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈជាប់ពីកំណើត ហើយគប្បីប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក ក្នុងស្មារតីភាតរភាពជាបងប្អូន។

**មាត្រា២:** មនុស្សម្នាក់ៗ អាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ ដែលមានចែងក្នុងសេចក្តីប្រកាសនេះដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ ។ លើសពីនេះ មិនត្រូវធ្វើការប្រកាន់បែងចែកណាមួយ ដោយសំអាងទៅលើឋានៈខាងនយោបាយ ខាងដែនសមត្ថកិច្ច ឬខាងអន្តរជាតិរបស់ប្រទេស ឬដែនដីដែលបុគ្គលណាម្នាក់រស់នៅ ទោះបីជាប្រទេស ឬដែនដីនោះឯករាជ្យក្តី ស្ថិតក្រោមអាណាព្យាបាលក្តី ឬគ្មានស្វ័យគ្រប់គ្រងក្តី ឬស្ថិតក្រោមការដាក់កម្រិតផ្សេងទៀតណាមួយដល់អធិបតេយ្យភាពក្តី ។

**មាត្រា៣:** បុគ្គលម្នាក់ៗ មានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន ។

**មាត្រា៤:** គ្មានជនណាម្នាក់ត្រូវស្ថិតក្នុងទាសភាព ឬស្ថិតក្នុងភាពជាអ្នកបម្រើដាច់ថ្លៃឡើយ។ ទាសភាព និងទាសពាណិជ្ជកម្មតាមគ្រប់ទម្រង់ទាំងអស់ ត្រូវហាមឃាត់ ។

**មាត្រា៥:** គ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម ឬការប្រព្រឹត្តិមកលើខ្លួន ឬទណ្ឌកម្មឯទៀតឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបបានឡើយ ។

**មាត្រា៦:** ជនគ្រប់រូប មានសិទ្ធិឱ្យគេទទួលស្គាល់ថាជាមនុស្ស នៅគ្រប់ទីកន្លែង ។

មាត្រា៧: ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារពីច្បាប់ស្មើៗគ្នាដោយគ្មានការរើសអើង ។ មនុស្សគ្រប់រូបមានសិទ្ធិទទួលការការពារស្មើៗគ្នាប្រឆាំងនឹងការរើសអើងណាដែលរំលោភលើសេចក្តីប្រកាសនេះ ព្រមទាំងប្រឆាំងនឹងការញុះញង់ឱ្យមានការរើសអើង ។

**មាត្រា៨:** មនុស្សគ្រប់រូបមានសិទ្ធិរកដំណោះស្រាយស័ក្តិសិទ្ធិមួយ នៅចំពោះមុខសាលាជំរះក្តីជាតិដែលមានសមត្ថកិច្ច ចំពោះអំពើទាំងឡាយណា ដែលរំលោភសិទ្ធិមូលដ្ឋានរបស់ខ្លួនដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់ ។

**មាត្រា៩:** គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួន តាមអំពើចិត្តឡើយ។

**មាត្រា១០:** មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញសុំឱ្យតុលាការឯករាជ្យ និងមិនលំអៀងពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ និងកាតព្វកិច្ច និងលើភាពសមហេតុផលនៃការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌមកលើខ្លួន ។

**មាត្រា១១:**

១. ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មត់ជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញ នៅក្នុងសវនាការជាសាធារណៈដែលមានការធានាចាំបាច់ ដើម្បីឱ្យជននោះការពារខ្លួន ។

២. គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌដោយអំពើឬការខកខានមិនបានធ្វើ បើអំពើឬការខកខាននេះ មិនបានចែងក្នុងច្បាប់ជាតិ ឬអន្តរជាតិថាជាបទល្មើសព្រហ្មទណ្ឌនៅពេលធ្វើអំពើ ឬមានការខកខាននេះ ។ ដូចគ្នានេះដែរ មិនត្រូវមានការផ្តន្ទាទោសឱ្យធ្ងន់ជាងទោសដែលបានកំណត់ឱ្យអនុវត្ត ក្នុងអំឡុងពេលដែលបទល្មើសបានកើតឡើងឡើយ ។

**មាត្រា១២:** គ្មានជនណាម្នាក់ ត្រូវរងការរំលោភជ្រៀតជ្រែកតាមអំពើចិត្ត ក្នុងជីវិតឯកជនគ្រួសារ ទីលំនៅ ឬការឆ្លើយឆ្លង ឬការធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនបានឡើយ ។ ជនគ្រប់រូបមានសិទ្ធិទទួលការការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ ។

**មាត្រា១៣:**

១. មនុស្សគ្រប់រូបមានសិទ្ធិធ្វើដំណើរដោយសេរីនិងមានសិទ្ធិជ្រើសរើសនិវេសនដ្ឋានក្នុងរដ្ឋមួយ

២. មនុស្សគ្រប់រូប មានសិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង និងមានសិទ្ធិវិលត្រឡប់មកប្រទេសរបស់ខ្លួនវិញ ។

**មាត្រា១៤:**

១. មនុស្សគ្រប់រូបមានសិទ្ធិស្វែងរក និងទទួលកន្លែងជ្រកកោនក្នុងប្រទេសដទៃទៀត ក្នុងករណីមានការធ្វើទុក្ខបុកម្នេញមកលើខ្លួន ។

២. សិទ្ធិសុំជ្រកកោននេះមិនអាចលើកមកសំអាងបានទេ ក្នុងករណីមានការចោទប្រកាន់ដែលពិតជាកើតឡើងពីបទល្មើសមិនមែននយោបាយ ឬពីការប្រព្រឹត្តណាដែលផ្ទុយពីគោលបំណង និងគោលការណ៏ទាំងឡាយរបស់សហប្រជាជាតិ ។

**មាត្រា១៥:**

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានសញ្ជាតិមួយ ។

២. គ្មានជនណាម្នាក់ អាចត្រូវដកហូតសញ្ជាតិ ឬរារាំងសិទ្ធិប្តូរសញ្ជាតិរបស់ខ្លួន តាមអំពើចិត្តបានឡើយ ។

**មាត្រា១៦:**

១. មនុស្សប្រុសស្រីដល់អាយុគ្រប់ការ មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងកសាងគ្រួសារដោយមិនប្រកាន់ពូជសាសន៍ សញ្ជាតិ ឬសាសនាឡើយ ។ មនុស្សប្រុសស្រី មានសិទ្ធិស្មើគ្នាក្នុងការរៀបអាពាហ៍ពិពាហ៍ ក្នុងចំណងអាពាហ៍ពិពាហ៍និងក្នុងពេលរំលាយចំណងអាពាហ៍ពិពាហ៍ ។
២. អាពាហ៍ពិពាហ៍នឹងអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរីនិងពេញលេញពីអនាគតប្តីប្រពន្ធ ។

៣. គ្រួសារជាអង្គភាពធម្មជាតិ និងជាអង្គភាពមូលដ្ឋាននៃសង្គម ហើយគ្រួសារមានសិទ្ធិទទួលការការពារពីសង្គម និងរដ្ឋ ។

**មាត្រា១៧:**

១. មនុស្សគ្រប់រូប ទោះតែម្នាក់ឯងក្តី ឬដោយរួមជាមួយអ្នកដទៃក្តីមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។

២. គ្មានជនណាម្នាក់ ត្រូវបានដកហូតកម្មសិទ្ធិ តាមអំពើចិត្តឡើយ ។

**មាត្រា១៨:** ជនគ្រប់រូប មានសិទ្ធិសេរីភាពខាងការគិត សតិសម្បជញ្ញៈ និងសាសនា ។ សិទ្ធិនេះ រាប់បញ្ចូលទាំងសេរីភាពផ្លាស់ប្តូរសាសនា ឬជំនឿ ព្រមទាំងសេរីភាពសម្តែងសាសនា ឬជំនឿរបស់ខ្លួនតែម្នាក់ឯង ឬដោយរួមជាមួយអ្នកដទៃជាសាធារណៈ ឬជាឯកជន តាមការបង្ហាត់បង្រៀន ការអនុវត្តន៍ ការគោរពបូជា និងការប្រតិបត្តិតាម ។

**មាត្រា១៩:** មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពក្នុងការប្រកាន់មតិ ដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានា ដោយគ្មានព្រំដែន ទឹកដី ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ។

**មាត្រា២០:**

១. មនុស្សគ្រប់រូប មានសិទ្ធិសេរីភាពក្នុងការប្រជុំ ឬការរួមគ្នាជាសមាគមដោយសន្តិវិធី ។

២. គ្មានជនណាម្នាក់ ត្រូវបានបង្ខិតបង្ខំឱ្យចូលរួមក្នុងសមាគមណាមួយឡើយ ។

**មាត្រា២១:**

១.មនុស្សគ្រប់រូប មានសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈនៃប្រទេសរបស់ខ្លួនដោយផ្ទាល់ ឬតាមរយៈតំណាងដែលបានជ្រើសរើសដោយសេរី ។

២. មនុស្សគ្រប់រូប មានសិទ្ធិចូលបម្រើមុខងារសាធារណៈនៃប្រទេសរបស់ខ្លួន ក្នុងលក្ខខណ្ឌសមភាព ។

៣. ឆន្ទៈរបស់ប្រជាពលរដ្ឋ ជាមូលដ្ឋានអំណាចនៃការដឹកនាំកិច្ចការសាធារណៈ ។ ឆន្ទៈនេះត្រូវសម្តែងចេញតាមរយៈការបោះឆ្នោតទៀងទាត់ តាមពេលកំណត់ និងពិតប្រាកដដែលមានលក្ខណៈសកល ស្មើភាពនិងសម្ងាត់ឬតាមនីតិវិធីសមមូលដែលធានាសេរីភាពនៃការបោះឆ្នោត។

**មាត្រា២២:** ក្នុងឋានៈជាសមាជិកសង្គម មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសន្តិសុខសង្គម និងមានបុព្វសិទ្ធិសម្រេចបានសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលចាំបាច់សម្រាប់សេចក្តីថ្លៃថ្នូរ និងការរីកចំរើនដោយសេរីនៃបុគ្គលិកលក្ខណៈរបស់ខ្លួនតាមរយៈការខិតខំរបស់ជាតិ និងសហប្រតិបត្តិការអន្តរជាតិនិងដោយយោងទៅតាមការរៀបចំនិងធនធានរបស់ប្រទេសនីមួយៗ

**មាត្រា២៣:**

១. មនុស្សគ្រប់រូប មានសិទ្ធិមានការងារធ្វើ ជ្រើសរើសការងារដោយសេរី ទទួលលក្ខខណ្ឌការងារត្រឹមត្រូវ និងពេញចិត្ត និងមានការការពារប្រឆាំងនឹងភាពអត់ការងារធ្វើ ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សស្មើគ្នា ចំពោះការងារដូចគ្នាដោយគ្មានការរើសអើង ។

៣. អ្នកធ្វើការងារមានសិទ្ធិទទួលបានលាភការ ដោយសមធម៌និងពេញចិត្ត ដើម្បីធានាអត្ថិភាពរស់នៅរបស់ខ្លួន និងគ្រួសារ ឱ្យសមស្របនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងត្រូវបានបំពេញបន្ថែមទៀត ដោយមធ្យោបាយផ្សេងៗ នៃការការពារផ្នែកសង្គម ប្រសិនបើចាំបាច់ ។

៤. មនុស្សគ្រប់រូបមានសិទ្ធិបង្កើតសហជីព និងចូលរួមក្នុងសហជីពដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

**មាត្រា២៤:** មនុស្សគ្រប់រូបមានសិទ្ធិឈប់សម្រាកនិងលំហែកំសាន្ត រួមបញ្ចូលទាំងកម្រិតម៉ោងការងារសមហេតុផលនិងការឈប់សម្រាកដោយបានប្រាក់បៀវត្សតាមពេលកំណត់ទៀងទាត់។

**មាត្រា២៥:**

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ដើម្បីធានាសុខភាពនិងសុខុមាលភាពរបស់ខ្លួន និងគ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងសេវាសង្គមកិច្ចចាំបាច់ផ្សេងៗទៀត។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការគាំពារនៅពេលគ្មានការងារធ្វើ មានជំងឺ ពិការ មេម៉ាយ ឬពោះម៉ាយ ចាស់ជរា ឬនៅពេលបាត់បង់មធ្យោបាយធានាជីវភាព ដែលបណ្តាលមកពីកាលៈទេសៈផុតពីឆន្ទៈរបស់ខ្លួន ។

២. មាតុភាព និងកុមារភាព មានសិទ្ធិទទួលជំនួយនិងការថែទាំពិសេស។ កុមារគ្រប់រូប ទោះកើតពីឪពុកម្តាយមានខាន់ស្លាឬឥតខាន់ស្លាក្តី ត្រូវបានទទួលការការពារខាងសង្គមកិច្ចដូចគ្នា ។

**មាត្រា២៦:**

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការអប់រំ ។ ការអប់រំ ត្រូវឥតបង់ថ្លៃយ៉ាងហោចណាស់សម្រាប់ការអប់រំបឋមសិក្សា និងអប់រំមូលដ្ឋាន ។ ការអប់រំបឋមសិក្សា គឺជាកាតព្វកិច្ច ។ ការអប់រំខាងបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវរៀបចំឱ្យមានជាទូទៅ ។ ការអប់រំឧត្តមសិក្សាត្រូវបើកឱ្យចូលរៀនស្មើភាពគ្នា ដោយឈរលើមូលដ្ឋានសមត្ថភាព ។

២. ការអប់រំ ត្រូវសំដៅទៅរកការរីកលូតលាស់ពេញលេញនៃបុគ្គលិកលក្ខណៈរបស់មនុស្សនិងការពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ។ ការអប់រំនេះ ត្រូវលើកកំពស់ការយល់ដឹង ការអត់ឱនអធ្យាស្រ័យគ្នា និងមិត្តភាពរវាងប្រជាជាតិ និងក្រុមពូជសាសន៍ ឬក្រុមសាសនាទាំងអស់ ព្រមទាំងការអភិវឌ្ឍន៍សកម្មភាពរបស់សហប្រជាជាតិក្នុងការថែរក្សា សន្តិភាព ។

៣. មាតាបិតា មានសិទ្ធិជាអាទិភាពក្នុងការជ្រើសរើសប្រភេទនៃការអប់រំសម្រាប់បុត្រធីតារបស់ខ្លួន ។

**មាត្រា២៧:**

១. មនុស្សគ្រប់រូបមានសិទ្ធិចូលរួមដោយសេរី ក្នុងជីវភាពវប្បធម៌របស់សហគមន៍ អាស្រ័យផលសិល្បៈ និងចូលរួមចំណែកក្នុងវឌ្ឍនភាព វិទ្យាសាស្រ្ត និងក្នុងផលប្រយោជន៍ដែលបានមកពីវឌ្ឍនភាព ។
២. មនុស្សគ្រប់រូប មានសិទ្ធិទទួលបានការការពារផលប្រយោជន៍ខាងសីលធម៌ និងសម្ភារៈដែលបានមកពីផលិតកម្មខាងវិទ្យាសាស្រ្ត អក្សរសាស្រ្ត ឬសិល្បៈដែលជាស្នាដៃរបស់ខ្លួន ។
**មាត្រា២៨:** មនុស្សគ្រប់រូប មានសិទ្ធិទទួលបាននូវសណ្តាប់ធ្នាប់សង្គម និងអន្តរជាតិដែលធ្វើឱ្យសិទ្ធិ និងសេរីភាព ចែងក្នុងសេចក្តីប្រកាសនេះ អាចសម្រេចបានដោយពេញលេញ ។

**មាត្រា២៩:**

១. មនុស្សគ្រប់រូប មានករណីយកិច្ចចំពោះសហគមន៍ ដែលជាកន្លែងតែមួយគត់ដែលអាចបង្កើតបានការរីកចម្រើនដោយសេរី និងពេញបរិបូរណ៍នូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។

២. ក្នុងការប្រើប្រាស់សិទ្ធិ និងសេរីភាពរបស់ខ្លួន មនុស្សគ្រប់រូប ត្រូវស្ថិតនៅត្រឹមតែកម្រិតព្រំដែនដែលច្បាប់បានកំណត់ សំរាប់ធានាការទទួលស្គាល់ និងការគោរពសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ និងបំពេញសេចក្តីត្រូវការយ៉ាងត្រឹមត្រូវ ខាងសីលធម៌ សណ្តាប់ធ្នាប់សាធារណៈ និងសុខុមាលភាពទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យតែប៉ុណ្ណោះ ។

៣. តែយ៉ាងណាក៏ដោយ សិទ្ធិ និងសេរីភាពទាំងនេះ មិនអាចយកទៅប្រើប្រាស់ផ្ទុយនឹងគោលបំណង និងគោលការណ៍ទាំងឡាយរបស់សហប្រជាជាតិឡើយ ។

**មាត្រា៣០:** គ្មានបទបញ្ញត្តិណាមួយនៃសេចក្តីប្រកាសនេះ អាចត្រូវបានបកស្រាយតម្រូវថារដ្ឋណាមួយ ក្រុមណាមួយ ឬបុគ្គលណាម្នាក់ មានសិទ្ធិបែបណាមួយ ក្នុងការធ្វើសកម្មភាព ឬការប្រព្រឹត្តអំពើអ្វីមួយ ដែលសំដៅទៅបំផ្លិចបំផ្លាញនូវសិទ្ធិ និងសេរីភាពទាំងឡាយដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះឡើយ ។

# សិទ្ធិមនុស្ស
# សិទ្ធិយើង

ខួប៦០ឆ្នាំនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ១៩៤៨-២០០៨

៦០
សេចក្តីប្រកាស
ជាសកល
ស្តីពីសិទ្ធិមនុស្ស
១៩៤៨-២០០៨

សេចក្តីថ្លៃថ្នូរ និង
យុត្តិធម៌សំរាប់ទាំងអស់គ្នា

Copyright United Nations 2008.
Not an official United Nations document. NOT FOR SALE.
Published by the OHCHR Cambodia Country Office to mark
the 60th anniversary of the Universal Declaration.

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំកម្ពុជា ~ ភ្នំពេញ

P O Box 108, Phnom Penh
Tel. 855-23-993 590/91 or 855-23-987-671/72
Fax 855-23 212 579 or 855-23-213 579
Website: cambodia.ohchr.org Email: cambodia@ohchr.org